# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:00៧/0៧ របក.ភកចនយ**

### របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មីនា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មីនា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ដោយមានអង្គភាពសម្រប សម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែល បានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាង ក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ**

ក. <u>ការងាររដ្ឋបាល</u>

-រៀបចំលិខិតអញ្ជើញចូលរួមប្រជុំពិភាក្សា ស្តីពីការរៀបចំប្រព័ន្ធទិន្នន័យលើកកំពស់ការយល់ដឹងសិទ្ធិមូលដ្ឋាននៅកំរិតសហគមន៍ នៅថ្ងៃ ព្រហស្បតិ៍ ទី ២២ ខែ មីនា ឆ្នាំ ២០០៧ និងរៀបចំ ឯកសារពាក់ព័ន្ធ

- រៀបចំលិខិតអញ្ជើញចូលរួមប្រជុំ Sub-Group TWG និងរៀបចំឯកសារពាក់ព័ន្ធផ្សេងៗ

ខ. <u>ការងារកំណែទម្រង់</u>

- ប្រជុំពិនិត្យចុងក្រោយនូវ Project Profile និងពិភាក្សាអំពីដំណើរការនៃក្រុមការងារ Sub-Group/ TWG

-ប្រជុំពិគ្រោះយោបល់ជាមួយអង្គការ ក្រសួងស្ថាប័នពាក់ព័ន្ធសំខាន់ៗ ស្តីពីការរៀបចំប្រព័ន្ធទិន្នន័យ លើកកំពស់ការយល់ដឹងសិទ្ធិមូលដ្ឋាន នៅកំរិតសហគមន៍ដោយមានការសហការជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ (UNDP) នៅថ្ងៃ ព្រហស្បតិ៍ ទី ២២ ខែ មីនា ឆ្នាំ ២០០៧

- បញ្ចប់ការកែលំអរបាយការណ៍លើការស្ទង់មតិជំនួយផ្នែកច្បាប់ (ជាភាសាខ្មែរ)

- រៀបចំ Progress Report ឆមាសទី II សម្រាប់ GAP II
- ប្រជុំមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង ដែលជាអ្នកសម្របសម្រួលក្នុង Sub-Group នីមួយៗ ជាមួយ និងថ្នាក់ដឹកនាំ PMU និងទីប្រឹក្សាមកពី AusAid ដើម្បីស្វែងយល់អំពីរូបមន្ត ដើម្បីធ្វើអោយមុខ ងារសម្របសម្រួលមានប្រសិទ្ធិភាពខ្ពស់ ។

គ. ផ្សេងៗ

- ចូលរួមវគ្គបណ្តុះបណ្តាលច្បាប់ពាណិជ្ជកម្មអន្តរជាតិ (International Trade Law) រយៈពេល ៤ ថ្ងៃ ពីថ្ងៃទី ២៦ ដល់ ២៩ ខែ មីនា ឆ្នាំ ២០០៧ ដោយមានការឧបត្ថម្ភពីក្រសួងការបរទេស និងសហប្រតិបត្តិការសឹង្ហបុរី
- ទទួលជួបក្រុមការងារនៃធនាគារពិភពលោក (World Bank) ស្វែងយល់ពីបរិយាកាស នៃការកែ ទម្រង់ច្បាប់ និងតុលាការ
- ទទួលជួបអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោក (ILO) បង្ហាញ ពីគម្រោងបណ្តុះបណ្តាលជនជាតិភាគតិចនៅរតនគីរី
- ចូលរួមពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងកម្មវិធី AusAid នៅក្រសួងមហាផ្ទៃ។

**២-សន្និដ្ឋាន**

ក្នុងខែ មីនា ឆ្នាំ ២០០៦ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាព គ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានខិតខំបំពេញការងារយ៉ាងសកម្មក្នុងការរៀបចំមូលដ្ឋាន សម្រាប់ដំណើរការការងាររបស់ Sub-Group/TWG ដើម្បីរុញច្រានការអនុវត្តកម្មវិធី សកម្មភាព កំណែទម្រង់ច្បាប់ និងតុលាការ អោយបានខ្លាំងក្លា ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

- ដំណើរការងាររបស់ Sub-Group

-រៀបចំប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បន្តរៀបចំឯកសារសម្រាប់ការប្រជុំពាក់ព័ន្ធ និងការបង្កើតប្រព័ន្ធសូចនាករ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ និងការពង្រឹកតុលាការគំរូ

- បន្តបំពេញបន្ថែមឯកសារក្នុងសៀវភៅមគ្គុទេសសម្រាប់វិស័យយុត្តិធម៌
- តាមដានភាពជឿនលឿនការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ ។

*រាជធានី ភ្នំពេញ ថ្ងៃទី ខែ មេសា ឆ្នាំ ២០០៧*

អ្នកធ្វើរបាយការណ៍

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោងលាង

ហ៊្វឹង សុកុល

ស៊ុយ ម៉ុងលាង